# ច្បាប់

## ស្តីពី

## ការចាត់តាំងអង្គការ តុលាការនិងអយ្យការ

### បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

### តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

**មាត្រា ១** តុលាការប្រជាជន គឺជាអង្គការជំនុំជម្រះ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ រដ្ឋអាជ្ញាអមតុលាការធ្វើការចោទប្រកាន់ ប្តឹងតាមច្បាប់ទៅតុលាការ ធានាការប្តឹងទៅតុលាការ ការជំនុំជម្រះនិងការអនុវត្តន៍សាលក្រមឲ្យបានត្រឹមត្រូវ និងស្របច្បាប់ ។

សកម្មភាព នៃសាលាជម្រះក្តី និងអយ្យការ មានទិសដៅការពារអំណាចប្រជាជន និងនីត្យានុកូលភាពប្រជាធិបតេយ្យ រក្សាសន្តិសុខសាធារណៈនិងរបៀបរៀបរយសង្គម ការពារទ្រព្យសម្បត្តិសាធារណៈ ការពារសិទ្ធិសេរីភាព ជីវិត និងប្រយោជន៍ស្របច្បាប់របស់ពលរដ្ឋ ដើម្បីពង្រឹងឯករាជ្យជាតិ និងធានាការកសាងមាតុភូមិឈានជាជំហានៗ ឆ្ពោះឡើងសង្គមនិយម ។

នៅគ្រប់សកម្មភាពសាលាជម្រះក្តី ត្រូវជំរុញពលរដ្ឋអោយមានការស្មោះត្រង់ចំពោះមាតុភូមិ និងស្មោះត្រង់ចំពោះរបបនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ជំរុញពលរដ្ឋអោយគោរពទ្រព្យសម្បត្តិសាធារណៈ និងបទដ្ឋាន នៃការរស់នៅក្នុងសង្គម ដោយសម្បជញ្ញៈ ។

**មាត្រា ២** ត្រូវបង្កើតតុលាការប្រជាជនក្រុង និង ខេត្ត ដែលមានសមត្ថកិច្ចជំនុំជម្រះបទល្មើសព្រហ្មទណ្ឌនិងរឿងវិវាទរដ្ឋប្បវេណី ។

ក្នុងរឿងព្រហ្មទណ្ឌ តុលាការប្រជាជនក្រុង និងខេត្ត មានសមត្ថកិច្ចជំនុំជម្រះបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្តឡើងនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន ។

ក្នុងរឿងរដ្ឋប្បវេណីតាមគោលការណ៍ តុលាការប្រជាជនដែលមានសមត្ថកិច្ច គឺតុលាការ ដែលតាំងនៅខាងទីលំនៅចម្លើយ ។ តុលាការត្រូវធ្វើការផ្សះផ្សាជាបឋមរវាងគូក្តី ។ ប្រសិនបើការផ្សះផ្សាមិនបានសម្រេចត្រូវបញ្ជូនរឿងនោះទៅតុលាការជំនុំជម្រះ ។

ក្នុងករណីពិសេស រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្រគល់សមត្ថកិច្ចទៅអោយតុលាការប្រជាជនក្រុង ឬ ខេត្តណាមួយ ដើម្បីជំនុំជម្រះបទល្មើសព្រហ្មទណ្ឌ ឬ រឿងរដ្ឋប្បវេណី ណាមួយដែលកើតឡើងក្រៅរង្វង់សមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ៣** នៅអមតុលាការប្រជាជនក្រុង ឬ ខេត្ត ត្រូវបង្កើតអយ្យការមួយ ដែលទទួលបន្ទុកដូចតទៅ ៖

១-ទទួលរឿងព្រហ្មទណ្ឌ និងត្រួតពិនិត្យភស្តុតាង បញ្ជា ឬ ចុះផ្ទាល់ធ្វើការអង្កេត ស៊ើបសួរបន្ថែម ប្រសិនបើជាការចាំបាច់ ដើម្បីអោយបណ្តឹងជាអាជ្ញាបានត្រឹមត្រូវ និងស្របច្បាប់ ។ មានតែបទល្មើសព្រហ្មទណ្ឌជាក់ស្តែងដែលមានភស្តុតាងគ្រប់គ្រាន់ទេ ដែលអាចបញ្ជូនទៅជំនុំជម្រះផ្ទាល់តែម្តងបាន ។

២-ធ្វើលិខិតចោទប្រកាន់ ។ សម្រេចពីការចោទប្រកាន់ ឬ មិនចោទប្រកាន់ជនប្រព្រឹត្តបទល្មើស ។

៣-ប្រើសិទ្ធិអយ្យការនៅពេលជំនុំជម្រះ។

៤-ត្រួតពិនិត្យការអនុវត្តន៍សាលក្រម ពេលជំនុំជម្រះរឿងរដ្ឋប្បវេណី រដ្ឋអាជ្ញាអាចបញ្ចេញយោបល់របស់ខ្លួនបើយល់ឃើញថាជាការចាំបាច់ ។ ប៉ុន្តែក្នុងរឿងសំខាន់ៗខ្លះដែលមានទាក់ទងដល់របៀបរៀបរយសាធារណៈឬ ទ្រព្យសម្បត្តិសង្គម ឬ ជាប់ជំពាក់ដល់ផលប្រយោជន៍អនីតិជន និងអសមត្ថជន រដ្ឋអាជ្ញាត្រូវធ្វើអន្តរាគមន៍ដោយតាំងខ្លួនជាគូក្តីដើម ។

-ប្រសិនបើ រដ្ឋអាជ្ញាយល់ឃើញថា សាលក្រមរបស់តុលាការប្រជាជនក្រុង ឬ ខេត្ត សម្រេចដោយមានការភ័ន្តច្រឡំ រដ្ឋអាជ្ញា ត្រូវផ្ញើសាលក្រមនោះជាបន្ទាន់ដោយមានភ្ជាប់សំណើ និងយោបល់របស់ខ្លួនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីប្តឹងបដិសេធ ។

**មាត្រា ៤** ដើម្បីជំនុំជម្រះ សាលាជម្រះក្តី ត្រូវផ្អែកលើច្បាប់ក្នុងករណីគ្មានអត្ថបទច្បាប់សាលាជម្រះក្តីអនុវត្តគោលការណ៍ប្រហាក់ប្រហែល នៃច្បាប់ ឬ ផ្អែកលើគតិនៃរដ្ឋធម្មនុញ្ញ និងមាគ៌ានយោបាយបដិវត្តន៍ ។

**មាត្រា ៥** ដើម្បីជំនុំជម្រះ សាលាជម្រះក្តីត្រូវផ្អែកលើគោលការណ៍ ពលរដ្ឋគ្រប់រូបមានភាពស្មើគ្នាចំពោះច្បាប់ដោយឥតប្រកាន់ជនជាតិ ជំនឿសាសនា ភេទ និងឋានៈក្នុងសង្គម ។

**មាត្រា ៦** ទីប្រឹក្សាប្រជាជនចូលរួមក្នុងការជំនុំជម្រះរឿងព្រហ្មទណ្ឌ និងរឿងរដ្ឋប្បវេណី ។ ក្នុងពេលជំនុំជម្រះទីប្រឹក្សាប្រជាជនមានសិទ្ធិស្មើ នឹងចៅក្រម ។

ក្រុមប្រឹក្សាជំនុំជម្រះ ធ្វើការជាសមូហភាព និង សម្រេចសេចក្តីតាមមតិភាគច្រើន ។

**មាត្រា ៧** ការជំនុំជម្រះត្រូវធ្វើជាសាធារណៈ ។ ប៉ុន្តែក្នុងករណីខ្លះដែលត្រូវរក្សាការសម្ងាត់របស់រដ្ឋ ឬ សីលធម៌សង្គម ការជំនុំជម្រះអាចប្រព្រឹត្តទៅជាសម្ងាត់បាន ។

**មាត្រា ៨** សាលាជម្រះក្តីធានាអោយពលរដ្ឋ ដែលជាជនជតិភាគតិចប្រើភាសា និង អក្សររបស់ខ្លួនបាន ។

**មាត្រា ៩** សិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ ត្រូវបានធានា ។

ជនជាប់ចោទ មានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងមេធាវីណាមួយ ឬ អ្នកដទៃណាមួយអោយជួយការពារក្នុងករណីខាងក្រោយនេះ ត្រូវមានការយល់ព្រមពីតុលាការជាមុនសិន ។

ក្នុងរឿងសំខាន់ តុលាការត្រូវចាត់តាំងមេធាវី ឬ អ្នកការពារម្នាក់អោយជួយការពារជនជាប់ចោទ បើជនជាប់ចោទគ្មានលទ្ធភាពនឹងពឹងអ្នកការពារអោយជួយការពារខ្លួនបាន ។

ក្នុងរឿងរដ្ឋប្បវេណី គូក្តីមានសិទ្ធិពឹងមេធាវី ឬ អ្នកដទៃណាមួយអោយជួយការពារផលប្រយោជន៍របស់ខ្លួនបាន ។

**មាត្រា ១០** ក្នុងរឿងព្រហ្មទណ្ឌក៏ដូចជារឿងរដ្ឋប្បវេណីដែរ តុលាការប្រជាជនក្រុង ឬ ខេត្ត ជំនុំជម្រះជាលើកទី ១ និងជាលើកចុងក្រោយបង្អស់ ។

បើគូក្តីណា មិនសុខចិត្តនឹងសាលក្រមនេះអាចធ្វើពាក្យប្តឹងតវ៉ាទៅស្ថាប័នលើ ។

សាលក្រមកាត់ទោសប្រហារជីវិតត្រូវដាក់ជូនក្រុមប្រឹក្សារដ្ឋពិនិត្យនិងអនុម័តជាមុនសិន មុននឹងយកទៅអនុវត្ត

ជនដែលត្រូវកាត់ទោសប្រហារជីវិតមានសិទ្ធិសុំអនុគ្រោះទោសទៅក្រុមប្រឹក្សារដ្ឋ ក្នុងរយៈ៧ ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រម ។

**មាត្រា ១១** តាមគោលការណ៍ សាលក្រមនៃតុលាការប្រជាជនក្រុង និង ខេត្ត ត្រូវសម្រេចចំពោះមុខគូក្តី ។

ប្រសិនបើសាលក្រម ជាសាលក្រមកំបាំងមុខគូក្តីអាចប្តឹងជំទាស់បានក្នុងរយៈ១៥ ថ្ងៃ ។ រយៈពេលនេះគិតពីថ្ងៃដែលបានឲ្យដំណឹងពីសាលក្រមនោះដល់គូក្តីផ្ទាល់ខ្លួន ឬ ដល់ទីលំនៅរបស់គូក្តី ។

**មាត្រា ១២** អង្គការរដ្ឋ អង្គការសង្គម និងពលរដ្ឋ ត្រូវគោរពសាលក្រម និងសេចក្តីសម្រេចស្ថាពររបស់តុលាការប្រជាជនក្រុងនិងខេត្ត ។ អង្គការ ឬ ជនដែលទទួលខុសត្រូវ ក្នុងការអនុវត្តសាលក្រម និងសេចក្តីសម្រេច ត្រូវអនុវត្តឲ្យបានត្រឹមត្រូវ ។

នគរបាល ធានារ៉ាប់រងការអនុវត្តន៍ទោសពន្ធនាគារ និងទោសប្រហារជីវិត។

គណៈកម្មាធិការប្រជាជនបដិវត្ត និង សង្កាត់ទទួលបន្ទុកអនុវត្តសាលក្រម ឬ សេចក្តីសម្រេចក្នុងរឿងរដ្ឋប្បវេណី សាលក្រមសម្រេចពីទោសពិន័យជាប្រាក់ ឬ សម្រេចពីជម្ងឺចិត្ត ។

**មាត្រា ១៣** តុលាការប្រជាជនក្រុង និងខេត្ត ទទួលខុសត្រូវចំពោះគណៈកម្មាធិការប្រជាជនបដិវត្តក្រុង និងខេត្ត ហើយរាយការណ៍ពីសកម្មភាពរបស់ខ្លួនជូនអង្គការនេះ ។

**មាត្រា ១៤** នៅថ្នាក់ ឃុំ និងសង្កាត់ ការផ្សះផ្សារវាងគូក្តី ក្នុងរឿងរដ្ឋប្បវេណីត្រូវប្រគល់អោយគណៈកម្មាធិការប្រជាជនបដិវត្ត ។

**មាត្រា ១៥** នៅថ្នាក់ស្រុក គណៈកម្មាធិការប្រជាជនបដិវត្ត ត្រូវចាត់តាំងសមាជិករបស់ខ្លួនម្នាក់ដើម្បីទទួលបន្ទុកកិច្ចការតុលាការ ។ សមាជិករូបនេះត្រូវផ្សះផ្សាគូក្តីក្នុងរឿងរដ្ឋប្បវេណី ដែលគណៈកម្មាធិការប្រជាជនបដិវត្ត ឃុំ ផ្ញើមកអោយខ្លួន សមាជិករូបនេះសម្រេចពីការបំពានទៅលើបទបញ្ញត្តិស្តីពីរបៀបរៀបរយសាធារណៈ ហើយចំពោះបទល្មើសនេះ អាចធ្វើការព្រមាននៅក្នុងអង្គប្រជុំ នៃតំណាងប្រជាជនឃុំ ដល់ជនប្រព្រឹត្តល្មើស និងក្នុងករណីធ្ងន់ធ្ងរ អាចពិន័យជាប្រាក់ពី ពីររៀល ដល់ ២០ ម្ភៃរៀល ប្រាក់ដែលបានមកពីការពិន័យ ត្រូវបញ្ចូលទៅក្នុងថវិការដ្ឋ ។

**មាត្រា ១៦** នៅថ្នាក់សង្កាត់ ក៏ដូចជាថ្នាក់ស្រុកដែរ បើការផ្សះផ្សារវាងគូក្តីក្នុងរឿងរដ្ឋប្បវេណី មិនបានសម្រេច ត្រូវផ្ញើសំណុំរឿងនោះទៅតុលាការប្រជាជនក្រុង ឬ ខេត្ត ដើម្បីសម្រេច ។

**មាត្រា ១៧** តុលាការប្រជាជនក្រុង ឬ ខេត្ត ផ្តល់សេចក្តីណែនាំពីការងារតុលាការ ដល់គណៈកម្មាធិការប្រជាជនបដិវត្តស្រុក ឃុំ សង្កាត់ ។

**មាត្រា ១៨** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រួតពិនិត្យសាលក្រមទាំងអស់របស់តុលារប្រជាជនក្រុងនិងខេត្ត រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានសិទ្ធិប្តឹងបដិសេធសាលក្រម ដែលបានសម្រេចដោយមានការភ័ន្តច្រឡំហើយធ្វើសេចក្តីរាយការណ៍ទៅក្រុមប្រឹក្សារដ្ឋដើម្បីសម្រេច ។

**មាត្រា ១៩** ក្រុមប្រឹក្សារដ្ឋមានសិទ្ធិសម្រេចលើបណ្តឹងបដិសេធ ដែលធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្រុមប្រឹក្សារដ្ឋ យល់ឃើញថា បណ្តឹងបដិសេធនេះត្រឹមត្រូវតាមច្បាប់ត្រូវផ្ញើសំណុំរឿងនេះទៅតុលាការក្រុង-ខេត្តដដែលដើម្បីជំនុំជម្រះឡើងវិញ

**មាត្រា ២០** តុលាការប្រជាជនក្រុង ឬ ខេត្ត មានប្រធានម្នាក់ អនុប្រធានម្នាក់ ឬ ពីរនាក់ ហើយនិងចៅក្រម ។ នៅពេលជំនុំជម្រះលើកទី ១ និងជាលើកចុងក្រោយបង្អស់ ក្រុមប្រឹក្សាជំនុំជម្រះមានចៅក្រមម្នាក់ជាប្រធាន និងទីប្រឹក្សាប្រជាជនពីរនាក់ ។

ក្នុងនីតិវិធីជំនុំជម្រះសាឡើងវិញ ក្រុមប្រឹក្សាជំនុំជម្រះត្រូវមានចៅក្រមពីរនាក់ ដែលម្នាក់ជាប្រធាន និងទីប្រឹក្សាប្រជាជនបីនាក់ ហើយសុទ្ធតែអ្នកដែលមិនបានចូលរួមក្នុងការជំនុំជម្រះលើកទី១ និងលើកចុងក្រោយបង្អស់ ។

ក្នុងករណីដែលខ្វះចៅក្រម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវតែងតាំងចៅក្រមម្នាក់ នៃតុលាការប្រជាជនក្រុងឬខេត្ត ដែលនៅជិតខាងដើម្បីអោយចូលរួមក្នុងការជំនុំជម្រះសាឡើងវិញ ។

**មាត្រា ២១** នៅអមតុលាការប្រជាជនក្រុងឬខេត្តនីមួយៗ ត្រូវតែងតាំងរដ្ឋអាជ្ញាម្នាក់ រដ្ឋអាជ្ញារងម្នាក់ឬ ពីរនាក់ ។

**មាត្រា ២២** ប្រធានតុលាការ និងរដ្ឋអាជ្ញាអមតុលាការ ត្រូវបានជ្រើសរើសដោយគណៈកម្មាធិការប្រជាជនបដិវត្តក្រុង ឬខេត្ត ដោយមានកយល់ព្រមពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងត្រូវបានតែងតាំងដោយក្រុមប្រឹក្សារដ្ឋមន្ត្រី។

អនុប្រធាន ចៅក្រម និងរដ្ឋអាជ្ញារង ត្រូវបានចាត់តាំងដោយគណៈកម្មាធិការប្រជាជនបដិវត្តក្រុងឬខេត្ត ក្រោយពីបានសេចក្តីយល់ព្រម ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២៣** ក្រោមឱវាទប្រធានតុលាការប្រជាជនក្រុង ឬ ខេត្ត មានលេខាធិការ-ក្រឡាបញ្ជី ទទួលបន្ទុកការងារបច្ចេកទេសនៃសាលាជម្រះក្តី ។

នៅក្រោមឱវាទ រដ្ឋអាជ្ញាអមតុលាការប្រជាជនក្រុង ឬ ខេត្ត លេខាធិការ-ក្រឡាបញ្ជី ទទួលបន្ទុកការងារបច្ចេកទេស នៃអយ្យការ ។

កិច្ចការរដ្ឋបាលទូទៅ និងការគ្រប់គ្រងកិច្ចការផ្សេងៗទៀតត្រូវស្ថិតនៅក្រោមឱវាទរួមរបស់ប្រធានតុលាការ និងរដ្ឋអាជ្ញា។ ក្នុងករណីដែលគ្មានឯកភាពក្នុងការអោយយោបល់ យោបល់របស់ប្រធានត្រូវទុកជាយោបល់ដែលមានឧត្តមានុភាព ។

**មាត្រា ២៤** ចំនួនបុគ្គលិក នៃតុលាកាប្រជាជនក្រុងឬខេត្តនីមួយៗ ត្រូវកំណត់ដោយក្រុមប្រឹក្សារដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងដោយមានការយល់ព្រមពីអង្គការសាមី ។

**មាត្រា ២៥** បញ្ជីទីប្រឹក្សាប្រជាជនក្រុងឬខេត្តនីមួយៗ ត្រូវរៀបចំដោយគណៈកម្មាធិការរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ក្រុង ឬ ខេត្ត ដោយសហការជាមួយសហជីពកម្ពុជា យុវជនបដិវត្តកម្ពុជា និងសមាគមនារីកម្ពុជា ក្រុងឬខេត្ត នោះ ។ ចំនួនទីប្រឹក្សាប្រជាជនក្រុង ឬ ខេត្ត នីមួយៗ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២៦** បញ្ញាមេធាវី និងក្នុងការពារសង្គម ត្រូវរៀបចំដោយគណៈកម្មាធិការរណសិរ្សសាមគ្គី កសាងការពារមាតុភូមិកម្ពុជា ក្រុងឬ ខេត្ត ដោយសហការជាមួយសហជីពកម្ពុជា យុវជនបដិវត្តកម្ពុជា និងសមាគមនារីកម្ពុជា ក្រុង ឬ ខេត្ត នោះ ។

**មាត្រា ២៧** នគរបាលត្រូវទទួលបន្ទុកនៅជនជាប់ចោទ ទៅតុលាការនិងធានារបៀបរៀបរយនៅពេលជំនុំជម្រះ

**មាត្រា ២៨** ក្រឹត្យ - ច្បាប់ លេខ ០១ ក.ច ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០ ត្រូវទុកជានិរាករណ៍ ។

**ច្បាប់នេះ**

រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានអនុម័តនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
នាសម័យប្រជុំលើកទី២ នីតិកាលទី១ ។

**ប្រធានរដ្ឋសភា**
ហត្ថលេខា និង ត្រា
**ជា ស៊ីម**